# ភាពរីកចម្រើនផ្នែកការសម្តែងនិងការបង្រៀនព្រះធម៌

ខ្ញុំធ្លាប់ទៅសម្តែងព្រះធម៌នៅប្រទេសអូស្ត្រាលីចំនួន ៣ ដង គឺ

លើកទី ១ នៅថ្ងៃសៅរ៍ ១ កើត ខែពិសាខ ឆ្នាំច ព.ស.២៥៤៩ ត្រូវនឹងថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០០៦ រយៈពេល ២៨ ថ្ងៃ ។ កាលនោះខ្ញុំបង្រៀនពុទ្ធបរិស័ទ អំពីចិត្តបរមត្ថ ។

លើកទី ២ នៅថ្ងៃ ៣ រោច ខែចេត្រ ចុងឆ្នាំច ដើមឆ្នាំកុរ អដ្ឋស័ក ព.ស.២៥៥០ ត្រូវនឹងថ្ងៃទី ០៥ ខែមេសា ឆ្នាំ ២០០៧ រយៈពេលជាងមួយខែ ។ ក្នុងកាលនោះ ខ្ញុំបានបង្រៀនរូបបរមត្ថ នៅទីក្រុងម៉ែលប៊ន និងកម្មកថានៅទីក្រុងស៊ីដនី ។

លើកទី ៣ នៅថ្ងៃពុធ ០៧ កើត ខែចេត្រ ចុងឆ្នាំជូត ដើមឆ្នាំឆ្លូវ សំរឹទ្ធិស័ក ព.ស.២៥៥២ ត្រូវនឹងថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០០៩ រយៈពេលជាងមួយខែ ។ ក្នុងកាលនោះ ខ្ញុំបានបង្រៀនអំពីអក្ខរវិធី និងសិង្គាលកសូត្រ ។

ក្នុងដំណើរទៅកាន់ប្រទេសអូស្ត្រាលីទាំង ៣ លើក ក្រៅពីការបង្រៀន ខ្ញុំបានទទួលសម្តែងព្រះធម៌តាមគេហដ្ឋាន ស្ទើរតែរាល់ថ្ងៃ ។

នៅថ្ងៃសុក្រ ០៦ កើត ខែជេស្ឋ ឆ្នាំកុរ ព.ស.២៥៥១ ត្រូវនឹងថ្ងៃទី ០២ ខែមិថុនា ឆ្នាំ ២០០៦ ខ្ញុំបានទៅបើកវគ្គបង្រៀន នៅសាលាសិក្សាព្រះធម៌ព្រះសមណគោតម ស្រុកស្ទោង ខេត្ត កំពង់ធំ ។ វគ្គសិក្សាដំបូងនេះ មានរយៈពេលជាងមួយខែ ដោយ លើកយកព្រះធម្មបទ ៣០ ព្រះគាថាមកបង្រៀន ឲ្យស្រួបទៅនឹង អាយុរបស់ខ្ញុំ ៣០ ឆ្នាំគត់ ។ ខ្ញុំបានធ្វើកិច្ចការនេះរហូតមិនលះបង់ ដោយក្នុងមួយឆ្នាំទៅបើកវគ្គបង្រៀនពីរដង គឺ ក្រោយចូលឆ្នាំខ្មែរ ជាវគ្គវែង ដែលមានរយៈពេល ពីមួយខែទៅពីរខែ តាមការដែល អាចលៃបាន និងក្នុងព្រះវស្សាមួយសប្តាហ៍ ជូនកាលមុនកាន់បិណ្ឌ ជូនកាលក្រោយភ្ជុំបិណ្ឌ ។ ការងារនេះ ខ្ញុំបានប្រព្រឹត្តធ្វើជាប់ជានិច្ច អស់រយៈពេល ៤ ឆ្នាំហើយ ។

ក្នុងការបង្រៀន ៤ ឆ្នាំកន្លងមក សម្រាប់វគ្គវែងគឺ ឆ្នាំទី ១ បង្រៀនព្រះធម្មបទ ៣០ គាថា ឆ្នាំទី ២ បង្រៀនព្រះធម្មបទ ៣១ គាថា ឆ្នាំទី ៣ បង្រៀនព្រះធម្មបទ ៣២ គាថានិងមេរៀន ព្រះអភិធម្មស្តីអំពីចិត្តបរមត្ថ ឆ្នាំទី ៤ បង្រៀន ព្រះធម្មបទ ៣៣ គាថា និងមេរៀនព្រះអភិធម្មស្តីអំពីចិត្តបរមត្ថ ។ រីឯវគ្គខ្លី ៗ ជូនកាល ខ្ញុំយកព្រះសូត្រផ្សេង ៗ ដូចជាអាឡវកសូត្រជាដើមមកបង្រៀន

ជូនកាលក៏បន្តមេរៀនព្រះអភិធម្ម ។



នៅថ្ងៃទី ១២ ខែសីហា ឆ្នាំ ២០០៧ ខ្ញុំបានទៅបង្រៀនព្រះធម៌ស្ដីអំពីអកុសលធម៌ ៩ កង នៅវត្តខេមវ័ន ក្រុងកំពង់ចាម ខេត្តកំពង់ចាម តាមការស្នើសុំរបស់អតីតព្រះមេគណខេត្ត ព្រះនាម **យ៉ន់ សុខ** និងគណៈកម្មការវត្តខេមវ័ន ។ វគ្គសិក្សានេះមានរយៈពេល ១១ ថ្ងៃ ។

ក្រោយពេលបញ្ចប់វគ្គសិក្សាដំបូងនេះ គណៈកម្មការវត្តបានរៀបចំសុំច្បាប់បើកវគ្គរៀនសូត្រព្រះធម៌ ហើយសុំឲ្យខ្ញុំទៅបង្រៀនជារៀងរាល់ឆ្នាំ ។ ខ្ញុំក៏បានទទួលតាមសំណូមពរ ដោយក្នុងមួយឆ្នាំទៅបង្រៀនពីរវគ្គ គឺ វគ្គទី ១ មុនបុណ្យចូលឆ្នាំខ្មែរ និងវគ្គទី ២ មុនពេលចូលព្រះវស្សា ។ ការសិក្សានោះ ដូច្នេះគឺ :

នៅថ្ងៃទី ១២ ខែមេសា ឆ្នាំ ២០០៨ បានទៅបង្រៀនអំពីកម្មកថា រយៈពេល ៤១ ថ្ងៃ ។ រីឯវគ្គបន្តបន្ទាប់មក គឺបង្រៀនមេរៀនព្រះអភិធម្មរហូត ដែលចាប់ផ្ដើមអំពីចិត្តបរមត្ថ ។ ខ្ញុំបានប្រព្រឹត្តធ្វើនូវការងារនេះ រហូតមកដល់សព្វថ្ងៃ ។


សាលាសិក្សាព្រះធម៌វត្តខេមវ័ន ក្រុងកំពង់ចាម